

# ពូជប៉េងប៉ោះ នាងពេជ្រ



*ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម កម្ពុជា*

ពូជ នាងពេជ្រ គឺជាពូជប៉េងប៉ោះដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម កម្ពុជានាចុងឆ្នាំ ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ បច្ចុប្បន្ន ពូជប៉េងប៉ោះ នាងពេជ្រ បាននឹងកំពុងផ្សព្វផ្សាយ ក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លក្ខណៈពិសេសៗរបស់ពូជប៉េងប៉ោះ នាងពេជ្រ

**ការលូតលាស់:** ពូជ នាងពេជ្រ ជាពូជលូតលាស់មានកំណត់ បានន័យថា ក្រោយការប្រមូលផលដើមរបស់វានឹងងាប់។ ពូជនេះមានកម្ពស់ចាប់ពី ៦០ ស.ម ទៅ ១០០ ស.ម ដែលចាប់ចេញផ្កានៅរយៈពេល ៥៥ ថ្ងៃ ចេញផ្លែនៅរយៈពេល ៦២ ថ្ងៃ និងចាប់ផ្ដើមទុំនៅរយៈពេល ៨៥ ថ្ងៃ ក្រោយថ្ងៃដុះ។ គេអាចធ្វើការប្រមូលផលចំនួនពីរលើក ដោយលើកទីមួយអាចចាប់ផ្ដើមនៅរយៈពេល ២០-២៥ ថ្ងៃ ក្រោយចេញផ្លែ និងលើកទីពីរនៅរយៈពេលមួយសប្ដាហ៍ ឬពីរសប្ដាហ៍ក្រោយប្រមូលផលលើកទីមួយ។

**ភាពធន់នឹងកម្ដៅ:** ជាទូទៅ កសិករធ្វើការដាំដុះដំណាំប៉េងប៉ោះចាប់ពីរដូវទឹកសម្រក ឬរដូវរំហើយ (តុលា-មករា) ព្រោះបើដាំដុះក្នុងរដូវក្ដៅ (កុម្ភៈ-ឧសភា) តែងតែជួបប្រទះនូវការខូចខាតដែលបណ្ដាលមកពីអាកាសធាតុក្ដៅខ្លាំងធ្វើឲ្យដំណាំជ្រុះផ្កា និងអត្រាដាក់ផ្លែទាប។ ដោយឡែកពូជ នាងពេជ្រ អាចដាំដុះបានទាំងនៅរដូវទឹកសម្រក និងនៅរដូវក្ដៅ។ ការធន់នឹងកម្ដៅនេះអាចដោយសារពូជនេះមានឫសច្រើន ហើយចាក់ចូលជ្រៅទៅក្នុងដី។

**ភាពធន់នឹងជំងឺ:** ពូជ នាងពេជ្រ មានភាពធន់ទ្រាំទៅនឹងជំងឺវីរុសលឿងរួញស្លឹក ដែលជាជំងឺធ្ងន់ធ្ងរមួយដល់ដំណាំប៉េងប៉ោះ។

**ការទុកគ្រាប់ដាំបន្ត:** ពូជប៉េងប៉ោះ នាងពេជ្រ ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្តបន្ទាប់ទៀតបាន មិនដូចជាពូជអ៊ីប្រ៊ីដទេ។

**ទិន្នផល:** ទិន្នផលរបស់ពូជ នាងពេជ្រ អាចខ្ពស់ជាងទិន្នផលរបស់ពូជអ៊ីប្រ៊ីដមួយចំនួន ដែលកសិករទិញពីផ្សារ។ ក្នុងរដូវក្ដៅបាន ផលជាមធ្យម ១៩ តោន ក្នុងមួយហិកតា ឯក្នុងរដូវរំហើយបានរហូតដល់ ៣០ តោន ក្នុងមួយហិកតា។

**លក្ខណៈផ្លែ:** ផ្លែមានរាងពងក្រពើ មានទម្ងន់ជាមធ្យម ៥៥ ក្រាម។ នៅពេលខ្ចីផ្លែមានពណ៌បៃតង និងមានពណ៌ក្រហមនាពេលទុំ។ សាច់ខាងក្នុងពណ៌លឿងទុំ។ នាពេលទុំផ្លែប៉េងប៉ោះពូជនេះមានរសជាតិឆ្ងាញ់។ មានកម្រាស់សាច់មធ្យមដែលអាចធន់ទ្រាំនឹងការប្រេះផ្លែ សមស្របសម្រាប់ការហូបជាបន្លែស្រស់ដូចជាធ្វើឡុកឡាក់ជាដើម និងមានបរិមាណសារធាតុខនិជចិញ្ចឹមប្រមាណ ៥,៥ ភាគរយ។ ផ្លែដែលស្រគាល អាចរក្សាទុកបានដល់ ១២ ថ្ងៃ ក្នុងសីតុណ្ហភាពធម្មតា។



## វិធីសាស្ត្រដាំដុះ

កូនប៉េងប៉ោះត្រូវបណ្ដុះនៅលើកន្ទោងរហូតដល់អាយុបាន ២០ ទៅ ៣០ ថ្ងៃទើបយកទៅដាំ។ ចន្លោះពីដើមមួយទៅដើម មួយគឺ ៥០ ស.ម និងចន្លោះជួរគឺ ១០០ ស.ម។ រងដំណាំមានទទឹង ១ ម៉ែត្រ បណ្ដោយ ៥ ម៉ែត្រ និងកម្ពស់ ២០ ស.ម។ ចំពោះការដាំដុះក្នុងរដូវវស្សា (ឧសភា-សីហា) ទាមទារឲ្យមានកាលើករងកម្ពស់ ២៥ -៣០ ស.ម ហើយប្រសិនបើអាច គ្របរងដោយគម្រប ចំបើង ឬផ្លាស្ទិករឹតតែប្រសើរ។ នៅពេលដំណាំចាប់ចេញកញ្ចុំផ្កា (ប្រមាណពីរសប្ដាហ៍ក្រោយដាំ) ត្រូវចាប់ផ្ដើមដោតទ្រើង ឬចំណារដើម្បីទប់ដើម និងចង្កោមផ្លែកុំឲ្យបាក់នៅពេលផ្លែរបស់វារីកធំ។ ក្នុងផ្ទៃដីមួយហិកតា គេត្រូវការគ្រាប់ពូជប្រមាណ ២០០ ក្រាម ទៅ ៣០០ ក្រាម សម្រាប់ចន្លោះគុម្ពដូចខាងលើ។ ក្នុងផ្លែមួយចង្កោមគួរទុកត្រឹម ៤-៥ ផ្លែ ដើម្បីឲ្យផ្លែធំល្អ និងក្នុងមួយដើមគួរទុក ៥-៦ ចង្កោមបើមានដើមបែកច្រើន យើងគួរធ្វើកាត់វាចោលខ្លះ។



## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស នឹងនាំឲ្យទទួលបានទិន្នផលខ្ពស់ ព្រមទាំងគុណភាពផ្លែល្អ។ កម្រិតជីដែលអាចប្រើប្រាស់ គឺ ៧៥-៣០-១០០ គ.ក្រ ក្នុងមួយហិកតា នៃ N : $P_2O_5$ : $K_2O$។ ការប្រើប្រាស់ជីអាចលើសពីនេះ អាស្រ័យទៅតាមកម្រិតជីជាតិរបស់ដី។ ការបាចជីអាចចែកជាបីលើកគឺទ្រាប់បាតមុនដាំ (៥០ ភាគរយ) បំប៉នលើកទីមួយពេលចេញផ្កា ២៥ ភាគរយ និងបំប៉នលើកទីពីរក្រោយប្រមូលផលលើកទីមួយ ២៥ ភាគរយ នៃជីទាំងបីប្រភេទ។

## ការប្រមូលផល

នៅពេលផ្លែ ចាប់ផ្ដើមប្រែទៅពណ៌ក្រហមបាន ១០-២០ ភាគរយ ឬនៅរយៈពេល ២០-២៥ ថ្ងៃ ក្រោយចេញផ្លែគេអាចធ្វើការប្រមូលផលបាន។ ការប្រមូលផលនៅដំណាក់កាលនេះ គឺអាចជួយកាត់បន្ថយការខូចខាតពេលដឹកជញ្ជូនបានមួយចំណែក និងអាចរក្សាទុកផ្លែបានច្រើនថ្ងៃ។



## ការទុកដាក់ក្រោយពេលប្រមូលផល

ការបាត់បង់ក្រោយពេលប្រមូលផលអាចបណ្ដាលមកពីកត្តាពីរ គឺទីមួយការបម្រែបម្រួលសារធាតុចិញ្ចឹមក្នុងផ្លែ និងទីពីរការខូចខាតដោយការប៉ះទង្គិច។ ដើម្បីចៀសវាងការបាត់បង់នេះ កសិករគួរធ្វើការប្រមូលផលទុកដាក់ និងដឹកជញ្ជូនឲ្យបានសមស្រប និងជាពិសេសត្រូវរើសផ្លែដែលខូច ដូចជាស្អុយ មានជំងឺ មានសត្វល្អិតបំផ្លាញ ជាំ ឬប្រេះ ដាក់ដាច់ដោយឡែកពីផ្លែដែលល្អ។

